# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុនតាណាកា ហ្វ័រសាយថ៍(ខេមបូឌា)អ៉ីន
អាស័យដ្ឋាន តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ
ឡូត P2-090 ភូមិបឹងធំ សង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ

ថ្ងៃព្រហស្បត៍5រោចខែជេស្ឋឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី10ខែមិថុនាឆ្នាំ២០២០

លេខ TF-005/20

## កិច្ចព្រមព្រៀងរវាងក្រុមហ៊ុននឹងប្រតិភូបុគ្គលិក
## ស្តីអំពី
## ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិកកំឡុងពេលរាតត្បាត់ជំងឺកូវីត ១៩

ដោយយោងតាមកំណត់ហេតុដែលបានធ្វើឡើង នៅថ្ងៃព្រហស្បតិ៍ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ដែលត្រូវនឹងថ្ងៃទី១០ខែមិថុនាឆ្នាំ២០២០នៅវេលា ម៉ោង១២នឹង៤០នាទី សហគ្រាសតាណាកា ហ្វ័រសាយថ៍(ខេមបូឌា)អ៉ីនបានធ្វើកិច្ចប្រជុំមួយជានឹងតំណាងកម្មករនិយោជិក មានប្រតិភូរបុគ្គលិកនឹងកម្មករនិយោជិកទាំងអស់។ក្នុងនោះផងដែរ តំណាងសហគ្រាសបានរៀបរាប់ពីមូលហេតុដែលបណ្តាលឲ្យមានការព្យួរកិច្ចសន្យាការងារឡើង ដោយសារតែ មានការរាតត្បាត់ខ្លាំងនៃជំងឺកូវិត១៩ នៅក្នុងប្រទេសទទួលទំនិញ ក៏ជាប្រទេសជាច្រើនទៀតទូទាំងពិភពលោក ដែលហេតុនាំឲ្យគ្មានការបញ្ជារទិញទំនិញ ពីប្រភពបរទេសធ្វើឲ្យសហគ្រាសបាត់បង់ចំណូលដែលមិនអាចផ្គត់ផ្គង់ រាល់ការចំណាយផ្សេងៗ ជាពិសេសថ្លៃពលកម្មដល់កម្មករនិយោជិកទាំងអស់បាន ។ ហេតុដូចនេះ ទើបក្រុមហ៊ុនសំរេចចិត្ត បន្តព្យួរកិច្ចសន្យាការងារកម្មករនិយោជិក ចំនួន 31នាក់ ក្នុងកំឡុង ១ខែ ដោយក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភ ដល់កម្មករនិយោជិកក្នុងម្នាក់៣០ដុល្លាជារៀងរាល់ខែ។ ការព្យួរកិច្ចសន្យានេះនឹងចាប់ផ្តើមពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០នេះ រហូតដល់ថ្ងៃទី ១៥ខែ កក្កដា ឆ្នាំ២០២០ ។ ការប្រជុំបានបញ្ចប់នៅវេលាម៉ោង ០១នឹង១០ នាទី ។

កិច្ចព្រមព្រៀងនេះធ្វើឡើងដោយមានការយល់ស្របទាំងនឹងមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

ដើម្បីជាសក្ខីភាពដែលបញ្ជាក់អំពីសេចក្តីរៀបរាប់ខាងលើនេះពិតជាត្រឹមត្រូវនឹងមិនមានការក្លែងបន្លំណាមួយ យើងខ្ញុំសូមផ្តិតមេដៃស្តាំ ទុកជាភ័ស្តុតាំង។

តំណាងកម្មករនឹងប្រតិភូរបុគ្គលិក

**តំណាងសហគ្រាស**

Mr.Haruhiko kakuno